ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០៤ សហវ

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១៥

# សេចក្តីណែនាំ

## ស្តីពីការអនុវត្តអត្រាពន្ធលើប្រាក់បៀវត្ស

អនុលោមតាមមាត្រា៤៧ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមធ្វើការណែនាំដូចតទៅ÷

### ១- រយៈពេលអនុវត្តនិងអត្រាកំណើនតាមថ្នាក់ថ្មី (Application Period and New Progressive Tax Rates)

គ្រប់សហគ្រាសដែលជាអ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម ស្ថាប័នរដ្ឋ និងអង្គការនានា ដែលមានកាតព្វកិច្ចកាត់ទុកនិងបង់ពន្ធលើប្រាក់បៀវត្ស (ពបវ) ត្រូវចាប់អនុវត្តអត្រាកំណើនតាមថ្នាក់ថ្មីចំពោះប្រាក់បៀវត្សដែលបើកជូននិយោជិតក្នុងខែមករា ឆ្នាំ២០១៥ ដែលនឹងត្រូវដាក់លិខិតប្រកាសបង់ប្រាក់ពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៥។

តារាងអត្រាកំណើនតាមថ្នាក់ថ្មីសម្រាប់គិត ពបវ មានដូចខាងក្រោម ÷

| ភាគបៀវត្សប្រចាំខែត្រូវជាប់ពន្ធ | | | | អត្រាពន្ធ |
|---|---|---|---|---|
| ពី | ០ ៛ | ដល់ | ៨០០ ០០០ ៛ | 0% |
| ពី | ៨០០ ០០១ ៛ | ដល់ | ១ ២៥០ ០០០ ៛ | ៥% |
| ពី | ១ ២៥០ ០០១ ៛ | ដល់ | ៨ ៥០០ ០០០ ៛ | ១០% |
| ពី | ៨ ៥០០ ០០១ ៛ | ដល់ | ១២ ៥០០ ០០០ ៛ | ១៥% |
| | | លើសពី | ១២ ៥០០ ០០០ ៛ | ២០% |

### ២- ទាយជ្ជទានសម្រាប់សហព័ទ្ធនិងកូនក្នុងបន្ទុក (Allowance for spouse and dependent children)

ផ្អែកលើការបង្ហាញភស្តុតាងនៃស្ថានភាពគ្រួសារ និយោជិតនិវាសនជនត្រូវបានទទួលទាយជ្ជទានសម្រាប់កាត់បន្ថយមូលដ្ឋានគិតពន្ធសម្រាប់ខែនីមួយៗ ចំពោះសហព័ទ្ធដែលធ្វើតែជាមេផ្ទះតែម្នាក់ចំនួន ៧៥ ០០០ រៀល និងកូនស្ថិតក្នុងបន្ទុកនាពេលដែលត្រូវបង់ពន្ធ ក្នុងម្នាក់ៗ ចំនួន ៧៥ ០០០ រៀល។

និយោជិតនិវាសនជនដែលមានសហព័ទ្ធដែលមិនមែនជាមេផ្ទះ ទាយជ្ជទានចំនួន ៧៥ ០០០ រៀល ខាងលើនេះមិនត្រូវបានផ្តល់ឱ្យទេ ហើយប្រសិនបើសហព័ទ្ធទាំងសងខាង (ប្តីនិងប្រពន្ធ) មានប្រាក់បៀវត្សជាប់ពន្ធទាំងពីរនាក់ ទាយជ្ជទានសម្រាប់កូនក្នុងបន្ទុកត្រូវបានផ្តល់ឱ្យតែម្ខាងប៉ុណ្ណោះ (ប្តីឬប្រពន្ធ)។

### ៣- ការគណនាពន្ធលើប្រាក់បៀវត្ស (The calculation of the Tax on Salary)

ក្នុងការគណនាពន្ធលើប្រាក់បៀវត្ស (ពបវ) ត្រូវរកមូលដ្ឋានគិត ពបវ ដោយយកប្រាក់បៀវត្សជាប់ពន្ធរបស់និយោជិតនិវាសនជននោះ ទៅដកចេញនូវទាយជ្ជទានសម្រាប់សហព័ទ្ធនិងកូនក្នុងបន្ទុកសិន ប្រសិនបើមាន។

បន្ទាប់មក ធ្វើការគណនាពន្ធលើប្រាក់បៀវត្ស ដោយយកមូលដ្ឋានគិតពន្ធ ដែលស្ថិតចំថ្នាក់អត្រាណាមួយ ទៅគុណនឹងអត្រានោះតែម្តង ដោយដកចេញនូវលម្អៀងលើសប្រាក់ពន្ធសម្រាប់ថ្នាក់នោះ។

ដូច្នេះ ពបវ = (មូលដ្ឋានគិតពន្ធ x អត្រាពន្ធ) - លម្អៀងលើសប្រាក់ពន្ធក្នុងថ្នាក់ដែលត្រូវកាត់ចេញ

ដែលក្នុងនោះ÷

១. មូលដ្ឋានគិតពន្ធ = ប្រាក់បៀវត្ស - ទាយជ្ជទាន

២. លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗត្រូវបានកំណត់ដូចខាងក្រោម÷

| **ភាគបៀវត្សប្រចាំខែត្រូវជាប់ពន្ធ** | **អត្រា** | **លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់** |
|---|---|---|
| ពី 0 ៛ ដល់ ៨00 000 ៛ | 0% | 0 ៛ |
| ពី ៨00 00១ ៛ ដល់ ១ ២៥0 000 ៛ | ៥% | ៤0 000 ៛ |
| ពី ១ ២៥0 00១ ៛ ដល់ ៨ ៥00 000 ៛ | ១0% | ១0២ ៥00 ៛ |
| ពី ៨ ៥00 00១ ៛ ដល់ ១២ ៥00 000 ៛ | ១៥% | ៥២៧ ៥00 ៛ |
| លើសពី ១២ ៥00 000 ៛ | ២0% | ១ ១៥២ ៥00 ៛ |

**ឧទាហរណ៍ទី១**- *និយោជិតម្នាក់មានប្រាក់បៀវត្ស ១ 000 000 រៀល*

១. ករណីនៅលីវ

មូលដ្ឋានគិតពន្ធ = ១ 000 000 - 0 = ១ 000 000 រៀល ត្រូវជាប់ពន្ធក្នុងអត្រា ៥%

ពបវ = (១ 000 000 x ៥%) - ៤0 000

= **១0 000** ៛

២. ករណីមានប្រពន្ធ

មូលដ្ឋានគិតពន្ធ = ១ 000 000 - ៧៥ 000 = ៩២៥ 000 រៀល ត្រូវជាប់ពន្ធក្នុងអត្រា ៥%

ពបវ = (៩២៥ 000 x ៥%) - ៤0 000

= **៦ ២៥0** ៛

៣. ករណីមានប្រពន្ធ និងកូន១

មូលដ្ឋានគិតពន្ធ = ១ 000 000 - (៧៥ 000 x ២) = ៨៥0 000 រៀល ត្រូវជាប់ពន្ធក្នុងអត្រា ៥%

ពបវ = (៨៥0 000 x ៥%) - ៤0 000

= **២ ៥00** ៛

៤. ករណីមានប្រពន្ធ និងកូន២

មូលដ្ឋានគិតពន្ធ = ១ 000 000 - (៧៥ 000 x ៣)= ៧៧៥ 000 រៀល ត្រូវជាប់ពន្ធក្នុងអត្រា 0%

នោះប្រាក់ពន្ធត្រូវបង់ក្នុងករណីនេះគឺ 0 ៛

**ឧទាហរណ៍ទី២**- *និយោជិតម្នាក់មានប្រាក់បៀវត្ស ៩ 000 000 រៀល*

១. ករណីនៅលីវ

មូលដ្ឋានគិតពន្ធ = ៩ 000 000 - 0 = ៩ 000 000 រៀល ត្រូវជាប់ពន្ធក្នុងអត្រា ១៥%

ពបវ = (៩ 000 000 x ១៥%) - ៥២៧ ៥00

= **៨២២ ៥00** ៛

២. ករណីមានប្រពន្ធ

មូលដ្ឋានគិតពន្ធ = ៩ ០០០ ០០០ - ៧៥ ០០០ = ៨ ៩២៥ ០០០ ត្រូវជាប់ពន្ធក្នុងអត្រា ១៥%

ពបវ = (៨ ៩២៥ ០០០ x ១៥%) - ៥២៧ ៥០០

= ៨១១ ២៥០ ៛

៣. ករណីមានប្រពន្ធ និងកូន១

មូលដ្ឋានគិតពន្ធ = ៩ ០០០ ០០០ - (៧៥ ០០០ x ២) = ៨ ៨៥០ ០០០ ត្រូវជាប់ពន្ធក្នុងអត្រា ១៥%

ពបវ = (៨ ៨៥០ ០០០ x ១៥%) - ៥២៧ ៥០០

= ៨០០ ០០០ ៛

៤. ករណីមានប្រពន្ធ និងកូន២

មូលដ្ឋានគិតពន្ធ = ៩ ០០០ ០០០ - (៧៥ ០០០ x ៣) = ៨ ៧៧៥ ០០០ ត្រូវជាប់ពន្ធក្នុងអត្រា ១៥%

ពបវ = (៨ ៧៧៥ ០០០ x ១៥%) - ៥២៧ ៥០០

= ៧៧៨ ៧៥០ ៛

វិធីសាស្ត្រសម្រាប់គណនាពន្ធលើប្រាក់បៀវត្សអាចមានរបៀបផ្សេងទៀត ប៉ុន្តែវិធីសាស្ត្រដូចបានបង្ហាញខាងលើនេះគឺជាវិធីសាស្ត្រសាមញ្ញងាយយល់។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សង្ឃឹមយ៉ាងមុតមាំថា គ្រប់សហគ្រាសដែលជាអ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម ស្ថាប័នរដ្ឋ និងអង្គការនានាដែលមានកាតព្វកិច្ចកាត់ទុកនិងបង់ពន្ធលើប្រាក់បៀវត្ស (ពបវ) ពិតជាយកចិត្តទុកដាក់ចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះប្រកបដោយប្រសិទ្ធភាព។

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**ចម្លងជូន៖**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  "ដើម្បីអនុវត្ត"
- អង្គការ សហគ្រាស និងក្រុមហ៊ុននានា
- ឯកសារ-កាលប្បវត្តិ